# បច្ចេកទេសផលិតកូនបង្កងពូជ

## Seed Production Technique of Giant Freshwater Prawn

(*Macrobrachium rosenbergii*)





សហគមន៍អឺរ៉ុប កម្មវិធីស្បៀងអាហារ

FAO EU Food Facility Project

ស្របតាមគោលនយោបាយយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជាលើវិស័យកសិកម្ម និងធនធានទឹក កម្មវិធីស្បៀងអាហាររបស់សហភាពអឺរ៉ុបដែលហៅថា "គម្រោងបង្កើនសន្តិសុខស្បៀងសម្រាប់គ្រួសារកសិករដែលរងឥទ្ធិពលដោយសារការឡើងថ្លៃស្បៀងអាហារ" ក្រោមការជំនួយឧបត្ថម្ភពីសហភាពអឺរ៉ុប ដើម្បីពង្រឹងវិស័យកសិកម្ម និងអាហាររូបត្ថម្ភនៅតាមសហគមន៍។ ការពង្រឹងសម្ថតភាពដែលមានស្រាប់ដើម្បីអនុវត្តគោលការណ៍សន្តិសុខស្បៀង និងផ្តល់សេវាកម្មអប់រំបន្ថែមសុទ្ធសឹងតែជាការបង្កើតទិន្នផលកសិកម្មដល់គ្រួសារកសិករដែលងាយរងឥទ្ធិពលដោយសារ ការឡើងថ្លៃស្បៀងអាហារតាមរយៈការពង្រឹងចំណេះដឹង និងផ្តល់សម្ភារៈកសិកម្មដែលមានគុណភាពខ្ពស់។ គម្រោងនេះគាំទ្រដោយ កម្មវិធីស្បៀងអាហាររបស់សហភាពអឺរ៉ុបដែលមានទឹកប្រាក់ចំនួន ១១.២ លានអឺរ៉ូ កំពុងអនុវត្តដោយអង្គការស្បៀងអាហារ និងកសិកម្មនៃសហប្រជាជាតិ ដោយរួមសហការជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

គោលបំណងចម្បងរបស់គម្រោងនេះ គឺដើម្បីពង្រឹងសន្តិសុខស្បៀងសម្រាប់ប្រជាពលរដ្ឋដែលងាយរងគ្រោះដោយសារការឡើងថ្លៃស្បៀងអាហារនៅក្នុងខេត្តគោលដៅចំនួន ៩ រួមមាន: ខេត្តបន្ទាយមានជ័យ កំពង់ស្ពឺ កំពង់ធំ ឧត្តរមានជ័យ ព្រះវិហារ ព្រៃវែង សៀមរាប ស្វាយរៀង និងតាកែវ។

---

ព័ត៌មានបន្ថែមសម្រាប់ការបណ្តុះបណ្តាល សូមទំនាក់ទំនងនាយកដ្ឋានអភិវឌ្ឍន៍វារីវប្បកម្ម នៃរដ្ឋបាលជលផល អាគារលេខ ១៨៥ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ប្រអប់សំបុត្រលេខ ៨៣៥
ទូរស័ព្ទ/ទូរសារ: ៨៥៥(០)២៣ ៩៥៦ ៣៨០
អ៊ីម៉ែល: chinda77@yahoo.com/leap_ad@yahoo.com

ការិយាល័យគម្រោង: អគ្គនាយកដ្ឋានកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាគារលេខ ៥៤ បេ ផ្លូវលេខ ៦៥៦ សង្កាត់ទឹកល្អក់ ៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ទូរស័ព្ទលេខ : ៨៥៥(០)២៣ ២១១ ៧០២/ ២១៦ ៥៦៦
ប្រអប់សំបុត្រលេខ: ៥៣ គេហទំព័រ: www.fao.org

# បច្ចេកទេសផលិតកូនបង្កងពូជ

## Seed Production Technique of Giant Freshwater Prawn


**រៀបរៀងដោយ**

លោក **ទ៊ាន់ ហេង** ប្រធានមជ្ឈមណ្ឌល

លោក **សំ ណារិទ្ធ** អនុប្រធានមជ្ឈមណ្ឌល

លោក **រស់ ណារិន** មន្ត្រីបច្ចេកទេសនៃមជ្ឈមណ្ឌល

**កែសម្រួលដោយ**

ឯកឧត្តម **ណៅ ធួក** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាប្រធានរដ្ឋបាលជលផល

ឯកឧត្តម **ស្រ៊ុន លឹមសុង** អនុប្រធានរដ្ឋបាលជលផល



**ឧបត្ថម្ភបោះពុម្ពផ្សាយដោយ**

រដ្ឋបាលជលផល និង MRC

ឆ្នាំ ២០១១

# មាតិកា


អារម្ភកថា........................................................................................ ២
១. សេចក្តីផ្តើម..................................................................................... ៣
២. លក្ខណៈជីវសាស្ត្របង្កងទឹកសាប.............................................................. ៣
២.១ ចំណាត់ថ្នាក់.................................................................................. ៣
២.២ លក្ខណៈរូបសាស្ត្រ............................................................................ ៤
២.២.១ លក្ខណៈខុសគ្នារវាងបង្កងញី និងឈ្មោល ................................................. ៥
២.៣ ចរិតស៊ីចំណី.................................................................................. ៥
៣. លក្ខខណ្ឌបរិស្ថាន.............................................................................. ៦
៤. ការបន្តពូជ...................................................................................... ៦
៥. ប្រភេទបង្កងមេពូជ ............................................................................ ៦
៥.១ បង្កងមេពូជធម្មជាតិ.......................................................................... ៦
៥.២ បង្កងមេពូជចិញ្ចឹមក្នុងស្រះ .................................................................. ៧
៦. ការរៀបចំស្រះបំប៉នមេពូជ .................................................................... ៧
៧. ចំណី និងការផ្តល់ចំណី......................................................................... ៨
៨. បច្ចេកទេសភ្ញាស់ពងបង្កង..................................................................... ៩
៨.១ ឧបករណ៍សម្ភារៈភ្ញាស់ពងបង្កង............................................................. ៩
៨.២ ដំណើរការភ្ញាស់ពងបង្កង ..................................................................... ៩
៨.៣ កំលាំងបន្តពូជ................................................................................. ១០
៨.៤ ការថែបំប៉នកូនបង្កង រហូតដល់ដំណាក់កាលជាបង្កងពូជ ................................ ១១
៨.៤.១ ប្រព័ន្ធផ្សាំកូនបង្កង ដោយទឹកបៃតង...................................................... ១១
៨.៤.២ ការរៀបចំធុង អាង ឬពាង និងឧបករណ៍................................................... ១១
៨.៤.៣ ការរៀបចំស្តុកកូនបង្កង..................................................................... ១២
៨.៤.៤ ការផ្តល់ចំណី................................................................................. ១២
៨.៤.៤.១ ចំណីផ្សំ ឬចំណីសប្បនិម្មិត............................................................. ១២
៨.៤.៤.២ ចំណីប្លង់តុងសត្វទឹកប្រៃ................................................................ ១៤
៩. ការងារគ្រប់គ្រង និងប្រមូលផល............................................................... ១៤
៩.១. លក្ខណៈកូនបង្កងមានសុខភាពល្អ.......................................................... ១៥
៩.២. ការប្រមូលផល................................................................................ ១៦
១០. បណ្ណាល័យសាស្ត្រ............................................................................ ១៦

# អារម្ភកថា

បង្កងទឹកសាប *(Macrobrachium rosenbergii)* ជាប្រភេទបង្កងធំមានរស់នៅតាមតំបន់ទឹកសាបនៃព្រះរាជាណាចក្រកម្ពុជា ប្រទេសថៃ ឡាវ វៀតណាម និងប្រទេសភូមា។ វាជាប្រភេទវារីសត្វដែលមានតំលៃសេដ្ឋកិច្ចខ្ពស់ ហើយជាទូទៅគេនិយមចូលចិត្តបរិភោគ។ បង្កងទឹកសាបក្នុងធម្មជាតិ បន្តពូជនៅតំបន់ទឹកភ្លាវតាមដៃសមុទ្រនានាដែលមានកំហាប់អំបិលពី ១០-១៥ ភាគពាន់។ ដូច្នេះ នៅក្នុងប្រទេសយើងមានតិចតួចនៅឯតំបន់ទឹកភ្លាវក្នុងខេត្តព្រះសីហនុ កំពត និងកោះកុង។ ដោយឡែក បង្កងនៅទន្លេមេគង្គវាផ្លាស់ទីទៅដៃសមុទ្រនៃប្រទេសវៀតណាម ក្នុងអំឡុងខែមេសា និងឧសភា ដើម្បីបន្តពូជ។ ក្រោយពេលមានទំហំពី ២.៥-៣.៥ សង្ទីម៉ែត្រ ទើបវាផ្លាស់ទីមកទន្លេមេគង្គលើវិញ។ ដូច្នេះហើយ ទើបនៅបឹងទន្លេសាបពុំមានវត្តមានបង្កងនៅទីនោះទេ។ បច្ចុប្បន្នដោយបានយកចិត្តទុកដាក់ពីរាជរដ្ឋាភិបាល ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ រដ្ឋបាលជលផលបានជំរុញអោយមានកិច្ចសហប្រតិបត្តិការស្រាវជ្រាវមួយរវាងមជ្ឈមណ្ឌលស្រាវជ្រាវ និងអភិវឌ្ឍវារីវប្បកម្មទឹកសាប ជាមួយគំរោងផ្សព្វផ្សាយ និងបង្កើនផលិតភាពវារីវប្បកម្មទឹកសាប (FAIEX) ឧបត្ថម្ភដោយអង្គការ JICA។ សកម្មភាពស្រាវជ្រាវផលិតបង្កងពូជខាងលើ បានអនុវត្តផ្ទាល់នៅមជ្ឈមណ្ឌលស្រាវជ្រាវ និងអភិវឌ្ឍវារីវប្បកម្មទឹកសាប ដោយផ្តើមនៅឆ្នាំ ២០០៥ ហើយទទួលបានជោគជ័យនៅឆ្នាំ ២០០៨។ ដោយឡែក យើងក៏បានសហការជាមួយបណ្តាវារីវប្បករផលិតបង្កងពូជចំនួន ០៣ កន្លែងទៀតនៅខេត្តតាកែវ។ ពួកគាត់ទាំងអស់សុទ្ធតែទទួលបានជោគជ័យដូចៗគ្នា។ ជំហានទីពីរនៃគំរោង ចាប់ពីឆ្នាំ ២០០៨ គឺជាការសាកល្បងចិញ្ចឹមបង្កងយកសាច់ ។

យើងខ្ញុំសង្ឃឹមថា សៀវភៅបច្ចេកទេសនេះនឹងជួយផ្តល់ជាគំនិតដល់អ្នកផលិតកូនបង្កងពូជ ដើម្បីចូលរួមចំណែកអភិវឌ្ឍផ្នែកវារីវប្បកម្មកម្ពុជា អោយបានរីកចំរើនកាន់តែប្រសើរឡើង ។

# ១. សេចក្តីផ្តើម

នៅក្នុងព្រះរាជាណាចក្រកម្ពុជាយើង ខេត្តដែលសំបូរបង្កងជាងគេ គឺខេត្តតាកែវ កណ្តាល និងព្រៃវែង ព្រោះខេត្តទាំងបីខាងលើ ស្ថិតនៅតាមដីសណ្តរទន្លេមេគង្គហើយមានព្រំប្រទល់ជាប់ទៅនឹងប្រទេសវៀតណាម ។ លក្ខខណ្ឌនៃភូមិសាស្ត្រខាងលើបានបង្កការងាយស្រួលក្នុងដំណើរការផ្លាស់ទីរបស់បង្កងទៅតំបន់ទឹកភ្លាវនៃប្រទេសវៀតណាម ដើម្បីភ្ញាស់ពង និងធំលូតលាស់ក្នុងតំណាក់កាលដំបូងនៅទីនោះ ។

លក្ខខណ្ឌក្នុងការផ្លាស់ទីរបស់បង្កងពីទន្លេមេគង្គទៅតំបន់ទឹកភ្លាវនៃប្រទេសវៀតណាម ដើម្បីភ្ញាស់ពង គឺវាទៅតែបង្កងញីទេ ព្រោះពងដែលនៅជាប់នឹងពោះរបស់វាបានផ្សំកំណើតរួចរាល់ហើយ ។ ក្រោយពីកូនបង្កងលូតលាស់បានប្រវែងពី ២.៥-៣.៥ សង្ទីម៉ែត្រ ទើបវាផ្លាស់ទីមកតំបន់វាលទំនាបទន្លេមេគង្គវិញ ដើម្បីស្វែងរកចំណីនៅតាមទន្លេ បឹងបួ និងព្រែកនានា ។ ក្នុងដំណើរតាមផ្លូវបញ្ច្រាសមកទន្លេមេគង្គលើវិញ កូនបង្កង និងបង្កងធំៗ ត្រូវបានអ្នកនេសាទស្ទាក់ចាប់ជាបន្តបន្ទាប់ ។ ដូចនេះហើយ ទើបនៅតំបន់កាន់តែឆ្ងាយក្នុងប្រទេសគេពុំសូវប្រទះឃើញមានវត្តមានបង្កងឡើយ ដូចជានៅខេត្តក្រចេះ ស្ទឹងត្រែង និងបណ្តាខេត្តទាំងប្រាំ នៅជុំវិញបឹងទន្លេសាប ។

ឡូត៍ដាយបង្កង មាននៅខេត្តព្រៃវែង ស្ថិតនៅតាមដងទន្លេតូចចំនួន ១៣ គន្លង ពីចំណុចភូមិបាទី ស្រុកពាមរក៍ រហូតដល់ឃុំកោះសំពៅ ស្រុកពាមជរ ។ ផលិតផលបង្កងធម្មជាតិ ត្រូវបានចុះថយ បើប្រៀបធៀបទៅនឹងទសវត្សឆ្នាំ ១៩៨០ ដោយសារការប្រែប្រួលធនធានជលផល កំណើនរបស់ប្រជាជន និងការធ្វើអាជីវកម្មនេសាទលើសកំរិត ។ បង្កងត្រូវបានចាប់ដោយដាយ លប និងសន្ទូច ដែលជាមធ្យមបានផលពី ២០-២៥ តោន/ឆ្នាំ (របាយការណ៍ស្ថិតិរដ្ឋបាលជលផល ឆ្នាំ ២០០៧) ។

បច្ចុប្បន្ន នៅតាមបណ្តាប្រទេសមួយចំនួនក្នុងតំបន់អាស៊ី និងអឺរ៉ុប កូនបង្កងពូជត្រូវបានផលិតនៅតាមស្ថានីយ៍នានា និងចិញ្ចឹមជាបង្កងសាច់សម្រាប់ផ្គត់ផ្គង់ជូនទីផ្សារ ។

# ២. លក្ខណៈជីវសាស្ត្របង្កង

## ២.១ ចំណាត់ថ្នាក់

បង្កង ត្រូវបានអ្នកវិទ្យាសាស្ត្រធ្វើចំណាត់ថ្នាក់ដូចខាងក្រោមនេះ :

- ថ្នាក់ (Class): CRUSTACEA
- អំបូរ (Family): PALAEMONIDAE
- ពូជ (Genus): Macrobrachium

- ប្រភេទ (Species): *Macrobrachium rosenbergii*
- ឈ្មោះពាណិជ្ជកម្ម (Common name): Giant Freshwater Prawn
- ឈ្មោះខ្មែរ : បង្កង

## ២.២ លក្ខណៈរូបសាស្ត្រ

ជាទូទៅបង្កងឈ្មោលធំជាងបង្កងមេ។ វាមានរាងមូលទ្រវែង ជាធម្មតាមានរាងខុប ដូចទំពក់ ដែលអាចងាយស្រួលក្នុងការរលាស់ខ្លួនដើម្បីផ្លាស់ទី។ វាមានប្រដាប់សម្រាប់ការពារខ្លួន ដូចជាទ្រនុងក្បាលដែលមានរាងស្រួច និងនៅសងខាងមានធ្មេញដូចផ្លែរណារ ដែលអាចការពារសត្រូវបាន។ ដោយឡែក ដង្កៀបវារឹងមាំ សម្រាប់ចាប់ចំណី និងការពារសត្រូវផង។ ខ្លួនវាគ្របដណ្តប់ដោយសំបក ដែលតភ្ជាប់ជាប្រាំមួយកង់ សម្រាប់បង្កការងាយស្រួលដល់ខ្លួនវាបត់បែនតាមតម្រូវការ ។

នៅដំណាក់កាលតូច ខ្លួនវាមានពណ៌ប្រផេះខ្ចី នៅពេលវាធំ ឬដំណាក់កាលពេញវ័យខ្លួនវាមានពណ៌ប្រផេះចាស់បន្តិច។ ដោយឡែក បង្កងឈ្មោលមានពណ៌ស្រស់ជាងហើយដង្កៀបវាមានពណ៌ខៀវ ធំជាងបង្កងញី។ មានពុកមាត់ចំនួនពីរគូសម្រាប់ស្រង់ក្លិនចំណី និងហេតុការផ្សេងៗដែលកើតមានឡើងជុំវិញខ្លួនវា ។

ភ្នែកវាមួយគូលៀនចេញក្រៅមានទម្រង់ដូចជាភ្នែកក្តាម មានពណ៌ខ្មៅ ដែលអាចមើលបានគ្រប់ទិស ហើយអាចលឺបចូលក្នុងវិញបាន។ បង្កងមេពេញវ័យក្នុងរយៈពេលពី ៥-៦ ខែ ដែលមានទំហំពី ១០ ក្រាមឡើងទៅ ឬមានប្រវែងពី ១០ សង្ទីម៉ែត្រឡើងទៅ។ ក្រោយពេលញាស់រហូតដល់អាយុ ២៧ ថ្ងៃ វាមានការវិវត្តន៍រូបរាងដោយឆ្លងកាត់ដំណាក់កាលសកចំនួន ១១ ដង។ ដំណាក់កាលនេះ វាមានប្រវែងពី ០.៨-១.០ សង្ទីម៉ែត្រ ដែលជាដំណាក់កាលហែលផ្ងាថយក្រោយ។ ក្រោយដំណាក់កាលនេះ ទើបវាហែលធម្មតា គឺហែលទៅមុខ។ ចំនួនសករបស់បង្កងធំតិចជាងបង្កងតូច ដើម្បីលូតលាស់សរីរាង្គរបស់វា។ ពេលសកម្តងៗខ្លួនវាទន់មិនអាចធ្វើចលនាបានឡើយ ហើយងាយរងគ្រោះថ្នាក់ពីសត្រូវរបស់វា។



*សកម្មភាពបង្កងបង្កាត់ពូជ*



*វដ្តជីវិតរបស់បង្កង*

## ២.២.១ លក្ខណៈខុសគ្នារវាងបង្កងញី និងឈ្មោល

**បង្កងឈ្មោល**

- មានក្បាលធំ
- មានដង្កៀបធំ និងដងខ្លួន ធំ
- នៅជើងទី ៥ ធំរឹងមាំ
- ប្រដាប់បន្តពូជស្ថិតនៅជើងទី៥

**បង្កងញី**

- មានក្បាលតូចជាង
- មានដង្កៀប និងដងខ្លួនតូចជាង
- ជើងខាងមុខ និងជើងសម្រាប់ហែលមានរោមច្រើន
- ប្រដាប់បន្តពូជស្ថិតនៅជើងទី ៣



*បង្កងឈ្មោល*




*បង្កងញី*

## ២.៣ ចរិតស៊ីចំណី

កូនបង្កងពូជ និងបង្កងពេញវ័យ (Juveniles and adults) រស់នៅតំបន់ទឹកសាបតាមទន្លេបឹងបួ ព្រែក ស្ទឹង ប្រឡាយទឹក និងវាលស្រែ។ល។ តែវាផ្លាស់ទីទៅតំបន់ទឹកភ្លាវិញដើម្បីភ្ញាស់ពង ចំណែកកូន (Post-larvae) ដែលមានអាយុលើសពីមួយខែ វានឹងធ្វើដំណើរឡើងទៅតំបន់ទឹកសាបវិញ ដើម្បីស្វែងរកចំណី និងរស់នៅទីនោះរហូតដល់ពេញវ័យ។

បង្កងជាសត្វដែលមានចរិតស៊ីចំណីចម្រុះ និងស៊ីសាច់ជាអាហារ (Omnivorous)។ កូនតូចទើបញាស់ នៅថ្ងៃទីពីរវាផ្តើមស៊ីកូនសត្វល្អិតតូចៗជាចំណីអាហារ។ ពេលវាធំអាចចាប់សត្វផ្សេងៗ ជាអាហារមានត្រី ឬស៊ីគ្នាវានៅពេលសក ផ្លែឈើផ្សេងៗ (ល្ហុង ទុយ



*សកម្មភាពបង្កងស៊ីចំណី*

ដូងដុត ឬពោត) ជាពិសេសចំណី ដែលមានក្លិនឈ្ងុយ ឬស្អុយ។ នៅកសិដ្ឋានចិញ្ចឹមបង្កង យើងអោយចំណីសិប្បនិម្មិត ដែលផ្សំឡើងអោយមានបរិមាណប្រូតេអ៊ីនពី ៣៨-៤០% ។ ជាទូទៅ វាចាប់ចំណីស៊ីនៅបាតដី ហើយមានសកម្មភាពល្អគឺនៅពេលយប់ វារហ័សរហួនជាងនៅពេលថ្ងៃ។ ដង្កៀបវា មានតួនាទីចាប់ចំណីបញ្ចូលទៅក្នុងមាត់ និងការពារខ្លួន។

## ៣. លក្ខខណ្ឌបរិស្ថាន

ជាទូទៅ បង្កងដែលមានអាយុលើសពីមួយខែឡើងទៅវាអាចរស់នៅបានក្នុងទឹកដែលមានកំហាប់អំបិលពី 0-២៥ ភាគពាន់ (0-២៥ ក្រាម/ លីត្រទឹក)។ ចំណែកកូនបង្កងក្រោមអាយុមួយខែ អាចរស់បានក្នុងទឹកដែលមានកំហាប់អំបិលពី ៦-១៦ ភាគពាន់ (៦-១៦ ក្រាម/លីត្រទឹក)។ វាក៏ជាប្រភេទសត្វដែលអាចស្រូបយកអុកស៊ីសែនពីបរិយាកាសបាន ដើម្បីរស់នៅ។ ដោយឡែក វាធន់នឹងកម្រិតប្រែប្រួលសីតុណ្ហភាពពី ២៦-៣១ អង្សាសេ។ បរិមាណអុកស៊ីសែនសមស្របគឺចាប់ពី ៣ មីលីក្រាម/លីត្រទឹកឡើងទៅ ទើបមានកម្រិតលូតលាស់បានល្អ ។

## ៤. ការបន្តពូជ

- រដូវបន្តពូជមានការប្រែប្រួលទៅតាមតំបន់គឺពីខែមេសាដល់ខែមិថុនា និងពីខែសីហាដល់ខែ តុលា ។
- ការវិវត្តន៍របស់កន្សោមពងមាន ៤ ដំណាក់កាល ដែលឋិតនៅក្នុងរយៈពេលពី ១៤-២០ ថ្ងៃ ។
- បង្កងញីឈ្មោលពាក់គ្នា ក្រោយពេលបង្កងញីសករួច ពី ៣-៤ ម៉ោង។
- ការបង្កាត់ពូជ មានរយៈពេលពី ២០-២៥ នាទី។ ពេលនោះ បង្កងញីវាទទួលយកមេជីវិតពីបង្កងឈ្មោល មករក្សាទុកនៅចន្លោះជើងទី ៣ ។
- ក្រោយពេលពាក់គ្នារួចពី២-៥ម៉ោង បង្កងមេបានបញ្ចេញពងមកភ្ជាប់នឹងពោះរបស់វាដោយឆ្លងមេជីវិតពីបង្កងឈ្មោល ពេលនោះពងត្រូវបានផ្សំកំណើត ។
- បង្កងមេអាចបង្កាត់ពូជលើកទីពីរបាន ក្រោយរយៈពេលពី ៣០-៤៥ ថ្ងៃ នៅក្នុងលក្ខខណ្ឌនៃការថែបំប៉នបានល្អ ចំណីមានគុណភាព និងបរិមាណគ្រប់គ្រាន់ ។

## ៥. ប្រភេទបង្កងមេពូជ

### ៥.១ បង្កងមេពូជធម្មជាតិ

គេអាចប្រើបង្កងដែលមានប្រភពពីធម្មជាតិជាមេពូជ គឺរើសយកបង្កងមេដែលមានពងស្រាប់ នៅខែ មេសា ទៅខែ មិថុនា។ បង្កងមេធម្មជាតិមានគុណសម្បត្តិ និងគុណវិបត្តិទន្ទឹមគ្នា គឺយើងអាចរើសយកបង្កងដែលមានទំហំធំ មានពងច្រើន តែភាគច្រើនៗមានសុខ

ភាពខ្សោយ គឺមានអត្រារស់ទាប ដោយសារបច្ចេកទេសចាប់ពីធម្មជាតិ និងការទុកដាក់ថែរក្សា មិនបានត្រឹមត្រូវ ។

## ៥.២ បង្កងមេពូជចិញ្ចឹមក្នុងស្រះ

បង្កងមេពូជក្នុងស្រះ មានលក្ខណៈសាំទៅនឹងមជ្ឈដ្ឋានរស់នៅ មានសុខភាពល្អក្នុង លក្ខខណ្ឌដែលមានដង់ស៊ីតេសមស្រប និងផ្តល់ចំណីមានគុណភាពល្អ ។ វាមានបរិមាណគ្រប់គ្រាន់ ទៅតាមផែនការដែលបានស្តុក និងថែបំប៉ន ងាយស្រួលរើសមេពូជដែលមានដំណាក់កាល ដូចៗគ្នា សម្រាប់យកមកភ្ញាស់តាមតម្រូវការ ដែលបានគ្រោងទុក ។



*ការបញ្ចូលទឹកស្រះដោយមានចម្រោះ*

## ៦. ការរៀបចំស្រះបំប៉នមេពូជ

ជារៀងរាល់ឆ្នាំ ស្រះត្រូវស្តារបាត ដើម្បីធ្វើអនាម័យសំអាត ដោយប្រមូលយក កាកសំណល់ផ្សេងៗចេញ ដូចជាលាមកបង្កង សំណកបង្កង និងកាកសំណល់ចំណីជាដើម ។ល ។ ការបន្សល់ទុកនូវកាកសំណល់ទាំងឡាយខាង លើបណ្តាលអោយខូចបរិស្ថាននៅបាតស្រះ ដែលបង្កអោយមានឧស្ម័នពុល ដូចជាឧស្ម័ន អ៊ីដ្រូស៊ុលហ្វួរ ($HSO_4$) មេតាន ($CH_4$) និងអាម៉ូនីញាក់ ($NH_3$) ជាដើម ។ល ។



*សកម្មភាពសំអាតបាតស្រះ*

ដូចនេះ ក្រោយពីបូមបាចពង្រីងស្រះ រួចត្រូវបាចកំបោរស ក្នុងបរិមាណពី ៥-៧ គីឡូក្រាមក្នុង ១០០ម$^2$ ។ ដើម្បីសម្លាប់ពពួក សត្វផ្សេងៗដែលមិនផ្តល់ផលល្អដល់ទឹកស្រះ រួចត្រូវហាលថ្ងៃឱ្យបានពី ២-៣ ថ្ងៃទើបបញ្ចូល ទឹក ។ ស្រះបង្កងមេពូជ គួរមានទំហំធំពី ៦០០-១២០០ ម$^2$ និងមានជម្រៅមធ្យមពី ១.០-១.៥ ម៉ែត្រ ។ បរិវេណជុំវិញស្រះត្រូវសំអាតឱ្យបានស្រឡះល្អ ចៀសវាងមានដើមឈើធំៗបាំងពន្លឺ ថ្ងៃ និងខ្យល់មិនអាចបក់បោកចូលបាន ។ កត្តា ខាងលើអាចជួយបន្ថែមបាននូវបរិមាណអុកស៊ី សែនរលាយក្នុងទឹកបានច្រើនជាង ។

បង្កងមេពូជដែលមានទំហំធំ និងមានអាយុពេញវ័យល្អ គឺចាប់ពី ៥ ខែឡើងទៅ ជា ពិសេសមានគ្រប់លក្ខណៈ មិនពិការរាងកាយ ត្រូវបានជ្រើសរើសធ្វើជាមេពូជ ។ យើងត្រូវ

រៀបចំ និងស្តុកបង្កងមេពូជក្នុងបរិមាណដង់ស៊ីតេពី ៤-៥ ក្បាល ក្នុងផ្ទៃស្រះ ១ ម៉ែ $^{២}$ ដោយស្តុកបង្កងញី និងឈ្មោលជាមួយគ្នាបានក្នុងសមាមាត្រ ២:៤ គឺ ឈ្មោល ២ និងញី ៤ ។

## ៧. ចំណី និងការផ្តល់ចំណី

ស្រះបង្កង ត្រូវរៀបចំកន្លែងសម្រាប់ផ្តល់ចំណីឱ្យបានត្រឹមត្រូវ ចៀសវាងការអោយចំណីដោយមិនកំណត់ទីកន្លែងបានច្បាស់លាស់ ។ ចំណីត្រូវមានគុណភាពល្អ និងមានបរិមាណប្រូតេអ៊ីនយ៉ាងតិច ៤០% ជាតិខ្លាញ់ពី ៨-១០% (Squid oil or bean oil) និងសារធាតុខនិជ ២% ។ ចំណីត្រូវជាប្រភេទលិចទឹក ព្រោះបង្កងមានចរិតស៊ីចំណីនៅបាតស្រះ។ ដូចនេះយើងអាចដាក់ចំណីនៅក្នុងកញ្ច្រែងហើយពន្លិចដល់បាតស្រះ ។ ចំណីត្រូវមានទំហំពី ៣-៥មីល្លីម៉ែត្រ ហើយឱ្យស៊ីនៅក្នុងបរិមាណពី ៥-១០% នៃទម្ងន់ដងខ្លួនមេ នៅក្នុងរយៈពេល ៦ ខែដំបូងលុះក្រោយមកត្រូវបន្ថយមកនៅត្រឹម ២-៣%វិញ។ ចំណីអាចត្រូវផលិតដោយខ្លួនឯង ឬក៏ប្រើចំណីគ្រាប់ ។



*ឧបករណ៍ផលិតចំណីគ្រាប់*



*ការហាលសម្ងួតចំណីគ្រាប់*

**តារាងទី១**

**ចំណីសម្រាប់បង្កងមេពូជ (១០០ គីឡូក្រាម) ដែលមានប្រូតេអ៊ីន ៤០%**

| ល.រ | សមាសធាតុផ្សំចំណី | បរិ.ប្រូតេអ៊ីនក្នុងធាតុផ្សំមួយៗ(%) | ភាគរយ (%) | បរិ.ប្រូតេអ៊ីនក្នុងចំណី (%) |
|---|---|---|---|---|
| ១ | ម្សៅត្រី | ៥៥ | ៦០ | ៣៣ |
| ២ | កន្ទក់ | ១២ | ២៤ | ២.៨៨ |
| ៣ | ចុងអង្ករ | ៥ | ៤.៥ | ០.២២៥ |
| ៤ | កាកសណ្តែកសៀង | ៣៩ | ១០ | ៣.៩ |

| | | | | |
|---|---|---|---|---|
| ៥ | អំបិល | | 0.៥ | |
| ៦ | វីតាមីនអ៊ី | | ១ | |
| | សរុប | ១00 | | ៤0.00 |

(Source: Dr. Tran Ngoc Hai, 2006)

# ៨. បច្ចេកទេសគ្នាស់ពងបង្កង

## ៨.១ ឧបករណ៍សម្ភារៈគ្នាស់ពងបង្កង

- កន្លែងផលិតកូនបង្កងពូជ ត្រូវតែមានដំបូលគត់មត់ការពារទឹកភ្លៀង ហើយស័ង្កសីសម្រាប់ប្រក់ដំបូលត្រូវមានពណ៌ភ្លឺថ្លា ពន្លឺអាចចាំងចូលបាន និងមានជញ្ជាំងបិទជិតដើម្បីថែរក្សាសីតុណ្ហភាពឱ្យនៅថេរពី ២៨-៣១ អង្សាសេ ។
- ធុងជ័ររាងមូល ឬពាងស៊ីម៉ង់ត៍ ដែលមានចំណុះពី 0.៥-១.0 ម$^{៣}$ សម្រាប់ផ្សាំកូនបង្កងរហូតដល់តំណាក់កាលជាកូនបង្កងពូជ ។
- ធុងជ័របួនជ្រុងតូចៗ ឬធ្វើពីកញ្ចក់ឬធុងដែលមានរាងមូល មានចំណុះជាមធ្យមពី៣0-១00 លីត្រ សម្រាប់ដាក់បង្កងមេដែលមានពងស្រាប់ អោយពងញាស់នៅក្នុងនោះ ។
- ប្រព័ន្ធខ្យល់អុកស៊ីសែនសម្រាប់បង្កើនគុណភាពទឹក ។
- ថង់សម្រាប់ច្រោះដែលមានក្រឡាទំហំ ១-៥ មីក្រូម៉ែត្រ (0.00១-0.00៥ មីល្លីម៉ែត្រ) ។ ថង់ច្រោះនេះ សម្រាប់ច្រោះទឹកឱ្យមានគុណភាពល្អ និងជាពិសេសច្រោះបួង់តុងរុក្ខជាតិសម្រាប់ប្រើប្រាស់ក្នុងការផ្សាំកូនបង្កង ។

## ៨.២ ដំណើរការគ្នាស់ពងបង្កង

យើងត្រូវជ្រើសរើសមេបង្កង ដែលមានពងក្នុងដំណាក់កាលដូចគ្នា ក្នុងបរិមាណដែល



ការពិនិត្យពងបង្កងជិតញាស់




ការប្រមូលកូនបង្កងក្រោយពេលញាស់

យើងត្រូវការ ។ ត្រូវរៀបចំដាក់មេបង្កងក្នុងដង់ស៊ីតេពី ៥-១០ ក្បាល/ម$^{២}$ នៅក្នុងធុង ឬកែវ ដែលទឹកមានគុណភាពល្អ មានកំហាប់អំបិលពី ១០-១២ ភាគពាន់ និងមានប្រព័ន្ធខ្យល់អុកស៊ីសែនបានគ្រប់គ្រាន់ ។ នៅពេលពងបង្កងវិវឌ្ឍរហូតជិតញាស់គឺវាមានពណ៌ប្រផេះក្រម៉ៅ ។ ជាទូទៅ កូនបង្កងញាស់នៅពេលយប់ ។ ព្រឹកឡើងយើងត្រូវប្រមូលវាដើម្បីស្តុកក្នុងអាងធុង ឬ ពាង ដើម្បីថែបំប៉នឱ្យទៅជាកូនបង្កងពូជ ។ វិធីគណនា ឬរាប់កូនបង្កងមានដូចខាងក្រោមនេះ :



*ការគណនាកូនបង្កងដោយវាល់*

- **ការគណនាដោយវាល់**
  យើងអាចយកខ្ទាតពី ៤-៥ សេសេ វាល់កូនបង្កងហើយរាប់ចំនួនវា ។ ធ្វើដូចនេះដដែលៗចំនួនបីដង និងគណនារកចំនួនមធ្យមភាគ ។
- **ការគណនាដោយថ្លឹង**
  យើងអាចថ្លឹង ដោយជញ្ជីងអេឡិចត្រូនិចដោយប្រើឯកត្តាជាក្រាម រាប់ចំនួនកូនបង្កងឱ្យដឹងមានចំនួនប៉ុន្មានក្នុង ១ ក្រាម ធ្វើដូចនេះដដែលៗចំនួនបីដង ហើយគណនារកចំនួនមធ្យមភាគ ។



*ការគណនាកូនបង្កងដោយថ្លឹង*

## ៨.៣ កម្លាំងបន្តពូជ



*មេបង្កងមិនទាន់ជម្រុះពង*



*មេបង្កងដែលជម្រុះពងរួច*

ជាទូទៅកម្លាំងបន្តពូជមានពី ៨០០-១២០០ គ្រាប់ពង/១០០ ក្រាមនៃទម្ងន់ដងខ្លួនមេ។ មេបង្កងមានទម្ងន់ជាមធ្យមពី ៥០-១០០ ក្រាម។ អត្រាញាស់ពងបង្កងគឺលើសពី ៩០% លើកលែងតែទឹកដែលដាក់ភ្ញាស់នោះ គ្មានគុណភាព ឬខ្វះអុកស៊ីសែន។ ពងបង្កងមានប្រវែងអង្កត់ផ្ចិត ជាមធ្យម 0.៩៨ មីលីម៉ែត្រ។

## ៨.៤ ការថែបំប៉នកូនបង្កង រហូតដល់តំណាក់កាលជាបង្កងពូជ (Post-larvae)

### ៨.៤.១ ប្រព័ន្ធផ្សាំកូនបង្កង ដោយទឹកបៃតង(Green water system)

ប្រព័ន្ធនៃការផ្សាំកូនបង្កងពីដំណាក់កាលទើបញាស់ ដល់កូនបង្កងពូជដែលមានរយៈពេលពី ២២-២៧ថ្ងៃ (Larvae stage to post-larvae) មានច្រើនប្រព័ន្ធ ដូចជាប្រព័ន្ធមានទឹកវិល (Recirculation System by bio-filter) និងប្រើទឹកបៃតង ដែលមានក្លរេលឡា (Chlorella) ជាមូលដ្ឋាន (Dugan et all, 1975; Smith et all, 1976)។ ក្លរេលឡាជាប្រភេទបួង់តុងរុក្ខជាតិ សំរាប់ធ្វើឱ្យមានលំនឹងគុណភាពទឹក ដោយវាស្រូបយកសារធាតុចិញ្ចឹមក្នុងធុង ឬអាងផ្សាំ ដោយបានពីកាកសំណល់ចំណី និងលាមកកូនបង្កង ។

ប្រព័ន្ធខាងលើនេះ តម្រូវឱ្យមានការផ្គត់ផ្គង់អុកស៊ីសែនគ្រប់ ២៤ ម៉ោង បើមិនដូច្នោះទេ កូនបង្កងនឹងងាប់ដោយខ្វះអុកស៊ីសែន។ ដូចនេះ យើងត្រូវត្រៀមដោយឡែកក្នុងការផលិតក្លរេលឡា។ ការផលិតក្លរេលឡា មានពីរដំណាក់កាល។ ដំណាក់កាលទី១ ត្រូវដាក់ត្រីទីឡាព្យ៉ាទៅក្នុងទឹកដែលមានកំហាប់អំបិលប្រមាណ ៥ ភាគពាន់ ចំនួន ៥-១០ ក្បាល/ម$^{៣}$។ ក្នុងរយៈពេលពី ៦-៧ ថ្ងៃ ទឹកដែលចិញ្ចឹមត្រីនោះនឹងឡើងពណ៌បៃតង។ ដំណាក់





*ការផលិតក្លរេលឡា*

កាលទី ២ ត្រូវផ្ទេរទឹកនោះទៅធុងផ្សេងទៀត ដោយឆ្លងកាត់ចម្រោះ ១-៥ មីក្រូម៉ែត្រ (0.00១-0.00៥ មីលីម៉ែត្រ) រួចបង្កើនកំហាប់អំបិលដល់ ១២ ភាគពាន់ ហើយបន្តការចិញ្ចឹមទៀត។ នៅក្នុងរយៈពេលចិញ្ចឹមត្រី ត្រូវឱ្យចំណីស៊ីធម្មតា ៥% នៃទម្ងន់ដងខ្លួន។

## ៨.៤.២ ការរៀបចំធុង អាង ឬពាង និងឧបករណ៍ផ្សេងទៀត

ទឹកដែលប្រើសម្រាប់ថែបំប៉នកូនបង្កង ត្រូវសំអាតដោយក្ល័រីនក្នុងបរិមាណ ៣០ ក្រាម/ម៉ែ³។ ទឹកនោះ ត្រូវដាក់ខ្យល់អុកស៊ីសែន រយៈពេលពី ៤-៥ ថ្ងៃ ចោល ដើម្បីឱ្យដំណើរការប្រតិកម្មរបស់ក្លរីនបានល្អ។ ក្រោយមក ត្រូវលាយជាមួយទឹកដែលមានក្លរេលឡា




ចម្រោះទឹក

ពី ៥-១០% នៃមាឌទឹកក្នុងធុង។ ទឹកបៃតង និងទឹកប្រៃដែលត្រូវយកទៅប្រើ ត្រូវឆ្លងកាត់ចម្រោះដែលមានទំហំពី ១-៥ មីក្រូម៉ែត្រ (0.00១-0.00៥ មីល្លីម៉ែត្រ)។ ធុង អាង ឬពាង ដែលត្រូវប្រើត្រូវលាងសំអាតដោយល្បាយក្លរីន ២00 មីល្លីក្រាម/លីត្រទឹកឱ្យបានមុនមួយថ្ងៃ ។

## ៨.៤.៣ ការរៀបចំស្តុកកូនបង្កង

ក្រោយពីបានប្រមូលកូនបង្កង ដែលមានអាយុស្មើគ្នារួចមក មុននឹងស្តុកថែបំប៉នត្រូវលាងសម្អាតជាមួយនឹងល្បាយហ្វ័រម៉ាលីន ២00មីល្លីក្រាម/លីត្រ ក្នុងរយៈពេលពី ២0-៣0 វិនាទី ជាមុនសិន។ កូនបង្កង ត្រូវស្តុកក្នុងដង់ស៊ីតេពី ៥0-៦0ក្បាល/លីត្រ (Sukot, J. et all ,1982) នៅក្នុងធុងសម្រាប់ថែបំប៉នកូនបង្កង ដែលបំពាក់ដោយប្រព័ន្ធខ្យល់អុកស៊ីសែនបានគ្រប់គ្រាន់ ។

## ៨.៤.៤ ការផ្តល់ចំណី

ចំណីសម្រាប់ថែបំប៉នកូនបង្កងមានពីរមុខគឺអាកតេម្យា និងចំណីផ្សំ។ ចំណីអាកតេម្យាផ្តល់នៅពេលល្ងាចសម្រាប់ឱ្យវាស៊ីនៅពេលយប់ ចំណែកចំណីផ្សំឱ្យវាស៊ីនៅពេលថ្ងៃ។ នៅថ្ងៃទីមួយមិនបាច់ឱ្យចំណីកូនបង្កងទេ។

### ៨.៤.៤.១ ចំណីផ្សំ ឬចំណីសិប្បនិម្មិត

ចំណីផ្សំត្រូវរៀបចំផលិតឡើងឱ្យមានគុណភាព និងមានប្រូតេអ៊ីនគ្រប់គ្រាន់សមាសភាគ ចំណីដែលត្រូវផ្សំមាន:

- ម្សៅទឹកដោះគោ ចំនួន ១០ ក្រាម
- ផ្នែកក្រហមនៃស៊ុតមាន់ ឬទា ចំនួន ១ គ្រាប់
- ប្រេងមឹក (Squid oil) ចំនួន ៣%
- ម្សៅឡេស៊ីទីន (lecithin) 1.5%
- វីតាមីនសេ ចំនួន ២០០-៥០០ មីលីក្រាម/១គីឡូក្រាម ចំណី

រូបមន្តជាទូទៅ បើគម្រោងថែបំប៉នកូនបង្គងចំនួន ១ លានកូន ត្រូវផលិតចំណីចំនួន ២០ គីឡូក្រាម និងអាកតេម្យា ចំនួន ៤ គីឡូក្រាម ។ ក្រោយពីផ្សំចំណីរួចតាមរូបមន្ត ត្រូវកូរបញ្ចូលគ្នាឱ្យស្មើល្អ រួចដាក់ចំហុយរយៈពេល ១៥ នាទី ដោយមានគម្របត្រឹមត្រូវ ។ ករណីគ្មានគម្រប ចំណីនោះនឹងរឹងលំបាកក្នុងការប្រើប្រាស់ ។ ចំណីត្រូវធ្វើឱ្យទៅជាគ្រាប់តូចៗតាមរយៈ




*សមាសធាតុផ្សំចំណី*



*ការចំហុយចំណី*




*ចំណីគ្រាប់ល្អិត*




*សមាសធាតុសម្រាប់ចំណីផ្សំ*

កញ្ច្រែងដែក ដែលមានទំហំពី ៣០០ មីក្រូម៉ែត្រឡើង (០.៣ មីលីម៉ែត្រ) តាមដំណាក់កាលកូនបង្គង ។

ពេលឱ្យចំណី ត្រូវបញ្ឈប់ខ្យល់ក្នុងធុងកូនបង្គង ដើម្បីឱ្យកូនបង្គងឡើងមកផ្ទៃលើងាយទទួលចាប់យកចំណីដែលយើងដាក់ឱ្យស៊ី ។

កម្មវិធីឱ្យចំណីផ្សំ (custarted) មានដូចខាងក្រោមនេះ :

- ពីថ្ងៃទី ៤-៥: ត្រូវឱ្យចំណីដែលមានទំហំពី ០.៣-០.៤ មីល្លីម៉ែត្រ
- ពីថ្ងៃទី ៦-៨: ត្រូវឱ្យចំណីដែលមានទំហំពី ០.៥-០.៦ មីល្លីម៉ែត្រ
- ពីថ្ងៃទី ៩-បង្កងពូជ (PL) ត្រូវឱ្យចំណីដែលមានទំហំពី ០.៧-១.០ មីល្លីម៉ែត្រ។ ពេលឱ្យចំណីស៊ីម្តងៗ ត្រូវផ្តល់ឱ្យសព្វ គឺកូនបង្កងទាំងអស់បានទទួលចំណី។ វិធីឱ្យចំណី ត្រូវលាយទឹកបន្តិចក្នុងចំណីដែលដាក់នៅក្នុងកែវ ដោយប្រើបំពង់បឺត ដើម្បីបឺតយកចំណី ហើយរលាស់ទៅក្នុងធុងកូនបង្កង។ នៅពេលឱ្យចំណី ត្រូវបញ្ឈប់ខ្យល់អុកស៊ីសែន តែត្រូវបើកវិញនៅពេលឱ្យចំណីរួច។ ចំណីខាង លើត្រូវឱ្យស៊ីចំនួនបួនដងក្នុងមួយថ្ងៃ ម៉ោង ៧.០០ ១០.០០ ១៤.០០ និងម៉ោង ១៦.៣០។



*សកម្មភាពឱ្យចំណីកូនបង្កង*

## ៨.៤.៤.២ ចំណីបួង់តុងទឹកប្រៃ (Artemia)



*ការភ្ញាស់អាកតេម្យា*

ចំណីបួង់តុងទឹកប្រៃ ឬអាកតេម្យា (Artemia) ជាចំណីដែលមានគុណភាពល្អ មានទំហំតូច ដែលកូនបង្កងទើបញាស់អាចស៊ីបាន និងរស់បានយូរ។ វារស់នៅក្នុងគីសបានយ៉ាងយូរ តែនៅពេលយើងត្រូវការវាធ្វើជាចំណីបង្កង ឬត្រី យើងត្រូវភ្ញាស់វា។ មុននឹងភ្ញាស់វាត្រូវលាងសម្អាតដោយហ៊្វរម៉ាលីន ក្នុងកំរិតដូស ២០០ មីល្លីក្រាម/លីត្រទឹក ក្នុងរយៈពេល ២០-៣០ វិនាទី ដើម្បីសម្លាប់ពួកភ្នាក់ងារចម្លងជម្ងឺ ដែលមានជាប់មក ជាមួយ។ ទឹកសម្រាប់ភ្ញាស់អាកតេម្យា ត្រូវមានកំហាប់អំបិល ពី ១០-១២ ភាគពាន់ និងមានបរិមាណអុកស៊ីសែនក្នុងទឹក បានគ្រប់គ្រាន់។ វាញាស់នៅក្នុងរយៈពេលពី ២០-២៤ ម៉ោង។ គីសអាកតេម្យាមានទំហំពី២០០-៣០០មីក្រូម៉ែត្រ (០.២-០.៣មីល្លីម៉ែត្រ) តែកូនទើបញាស់មានទំហំពី ៤០០-៥០០ មីក្រូម៉ែត្រ (០.៤-០.៥ មីល្លីម៉ែត្រ)។ គីសអាកតេម្យាស្ងួតអាចធន់ទ្រាំបាននៅក្នុងបរិយាកាសដែលមានសីតុណ្ហភាពខ្ពស់បំផុត ៨០ អង្សាសេ តែគីសសើមអាចងាប់នៅក្នុងសីតុណ្ហភាពពី ០-៤០ អង្សាសេ។

នៅថ្ងៃទី ២ ដល់ទី ៤ ត្រូវឱ្យចំណីអាកតេម្យា ពីរលើកក្នុងមួយថ្ងៃ ព្រឹកម៉ោង ៧ ម្តង និងល្ងាចម៉ោង ៥ ម្តង ដោយឱ្យក្នុងចំនួន ៥ ក្រាមគីស/ម$^{៣}$/ថ្ងៃ។ ចាប់ពីថ្ងៃទី ៥ ឡើងទៅ ត្រូវឱ្យចំណីអាកតេម្យាតែមួយពេល នៅម៉ោង៥ល្ងាច ក្នុងចំនួន៥-៧ ក្រាមគីស/ម$^{៣}$/ថ្ងៃ។ នៅក្នុងដំណាក់កាលនេះ ត្រូវបន្ថែមចំណីផ្សំ (custarted) ចំនួន ៤ដង ក្នុងមួយថ្ងៃគឺនៅម៉ោង

៧-១០ ព្រឹក និងម៉ោង ២-៤.៣០ ល្ងាច ។

## ៩. ការថែរក្សាគ្រប់គ្រង និងប្រមូលផល

បច្ចេកទេសផលិតកូនបង្កងពូជ ដោយប្រើប្រព័ន្ធទឹកថែបំប៉នដោយទឹកបៃតង គឺត្រូវតាមដាន និងគ្រប់គ្រងទឹកឱ្យមានពណ៌បៃតងជាប់ជានិច្ច។ ករណីមានការប្រែប្រួលដោយពណ៌ទឹកប្រែជាពណ៌ថ្លា ឬក្រមៅ គឺដោយសារក្លរ៉េលឡាមានជម្ងឺ ឬដោយសារមានវត្តមានរបស់ប្រូតូសត្វ (protozoa)។ យើងត្រូវធ្វើប្រព្រឹត្តិកម្ម ដោយប្រើហ្វ័រម៉ាលីនក្នុងកំរិត ៤៥ មីល្លីក្រាម/លីត្រ ទុករយៈពេល ២ ថ្ងៃ រួចថែមក្លរ៉េលឡាវិញ ។

ទឹកន្លែងផលិតកូនបង្កង ត្រូវធ្វើយ៉ាងណាថែរក្សាសីតុណ្ហភាពឱ្យថេរ ក្នុងកម្រិតពី២៨-៣១ អង្សាសេ។ ដូចនេះ ការសាងសង់ត្រូវមានពន្លឺចូលឱ្យបានគ្រប់គ្រាន់ និងឆ្ងាយពីភាពអ៊ូអររំខានដល់ការលូតលាស់កូនបង្កង។ នៅដំណាក់កាលកូនបង្កងក្លាយជាកូនបង្កងពូជរយៈពេលពី ២២-២៧ ថ្ងៃ ពេលនោះត្រូវបន្ថយកំហាប់អំបិលពី ៣-៤ ភាគពាន់/ថ្ងៃ រហូតដល់សូន្យ មុននឹងផ្ទេរចេញទៅស្រះផ្សាំ ឬស្រះចិញ្ចឹមសាច់ ។

នៅក្នុងប្រព័ន្ធផ្សាំទឹកពណ៌បៃតង ប៉េហាស់ (pH) ទឹក មានការប្រែប្រួលពី ៧.៥-៨.៥ តែបើប៉េហាស់ឡើងដល់ ៩ វាមានឥទ្ធិពលធ្វើឱ្យថយចុះដល់ការសករបស់កូនបង្កង។ ចំណែកឯបរិមាណអុកស៊ីសែនរលាយក្នុងទឹក ត្រូវរក្សាឱ្យបានយ៉ាងតិចពី ៥ មីល្លីក្រាម/លីត្រ ដោយប្រើប្រព័ន្ធខ្យល់ឱ្យបានគ្រប់គ្រាន់។ បរិមាណអាហ្សូត និងអាម៉ូញាក់កើនឡើងលើសកម្រិតកំណត់ដោយសារការឱ្យចំណីច្រើនហួសកំណត់។ ដូចនេះត្រូវតាមដានការប្រែប្រួលនូវបរិមាណអាហ្សូត ដោយវាស់ឱ្យបានទៀងពេល។

### ៩.១ លក្ខណៈកូនបង្កងមានសុខភាពល្អ

ការកត់សម្គាល់ចំពោះកូនបង្កងដែលមានសុខភាពល្អគឺ:

- កូនបង្កងទើបញាស់ ខ្លួនវាឡើងថ្លា តែចាប់ពីដំណាក់កាលទី ៤ ឡើងទៅ វាមានពណ៌ត្នោតភ្លឺ មិនមែនពណ៌ខ្មៅទេ ។
- នៅពេលបញ្ឈប់ខ្យល់អុកស៊ីសែន កូនបង្កងឡើងផ្ទៃលើភ្លាមស្ថិតនៅតាមជញ្ជាំងធុង អាង ឬពាង ។
- នៅពេលឱ្យចំណីផ្សំស៊ី វាចាប់ចំណីភ្លាម ហើយគេចចេញទៅកណ្តាលធុង អាង ឬពាង។ ចំណីដែលវាចាប់បាន វាស៊ីអស់ក្នុងរយៈពេលខ្លី ។
- នៅពេលយើងគោះធុង អាង ឬពាង កូនបង្កងភ្ញាក់ស្ទុះផ្លាស់ទីយ៉ាងលឿន ។
- នៅក្នុងរយៈពេល ២ ថ្ងៃម្តង យើងពិនិត្យឃើញមានសំណាកកូនបង្កងដែលសក

អណ្តែតនៅលើផ្ទៃទឹក ។

- ពោះវៀនវាពេញទៅដោយចំណី ។
- មិនឃើញមានងាប់នៅលើផ្ទៃទឹក ឬនៅបាតធុង អាង ឬពាង ។

## ៩.២ ការប្រមូលផល

កូនបង្កងដែលមានការលូតលាស់បានល្អ អាចសកបានគ្រប់ ១១ ដំណាក់កាល ក្នុងរយៈពេលពី ២២-២៧ ថ្ងៃ ហើយមានប្រវែងដងខ្លួនលើសពី ៧ មីល្លីម៉ែត្រ ជាពេលដល់ដំណាក់កាលកូនបង្កង (post-larvae) ត្រូវដាក់ជម្រកទៅក្នុងធុងសម្រាប់ការពារខ្លួន។ ដំណាក់កាលនេះត្រូវបន្ថយកំហាប់អំបិលរហូតដល់សូន្យ ហើយប្រមូលផលនៅថ្ងៃទី ៣០-៣៥។

ថ្ងៃដែលប្រមូលផលមិនត្រូវឱ្យចំណីទេ។ កូនបង្កងដែលប្រមូលផលហើយ អាចផ្សាំបន្តនៅក្នុងធុង ឬអាងដដែលពី ១០-១៥ថ្ងៃទៀត ដើម្បីឱ្យកូនបង្កងមានទំហំធំល្មមអាចស្តុកក្នុងស្រះចិញ្ចឹមយកសាច់បាន ។



*ការដាក់សំបុកជាជម្រកដល់កូនបង្កង*

## បណ្ណាល័យសាស្ត្រ


Aquacop, 1979. Mass production of Macrobrachium rosenbergii de Man freshwater prawn juveniles in French Polynesia: Predevelopment phase results. Centne oceanologique du Pacifique. CNEXO-COP., B.P. 7004 Taravao, Tahiti (French Polynesia): 10 pp.

Ardill, D., Jenson, R. Jugnarain, B. and Thomson, R. K., 1973. The introduction of freshwater prawn Macrobrachium rosenbergii de Man into Mauritius. Reprinted from revue Agricole et Sucriere de I'll Mau rice, 52:6-11.

Das, K. S. and J. B. Mookerji, 1995. Outlines of Biology. Pp: 187-217.

Dugan, C. C., Hagood, R. W. and Frakes, T. A., 1975. Development of spawning and mass larval rearing technique for brackish-freshwater shrimps of the genus Macrobrachium (Decapoda, Palaemonidae). Fla. Dept. Nat. Res., 12: 1-28.

Fujimura, T., 1974. Development of a prawn culture industry in Hawaii. Job completion report, U. S. Department of Commerce, NOAA, National Marine Fisheries Services: 13 pp.

Hai, T. N, 2006. Preparation of water and prawn brood stock of Macrobrachium rosenbergii.

Ling, S. W., 1969. The general biology and development of Macrobrachium rosenbergii de Man. In: M. N. Mistakidis (Ed.), proceedings of the world conference on shrimp and prawns (Mexico), 1967. FAO Ref. Pap E 30, FAO, Rom, pp. 589-606.

Singholka, S., 1978. Observations on the design, construction and management of small-scale or backyard hatchery for Macrobrachium rosenbergii de Man in Thailand. UNDP/FAO working paper THA:75:008/78/WP 1: 7 pp.

Smith, T. I. J., Sandifer, P. A. and Trimble, W. C., 1976. Progress in developing a recirculating synthetic seawater hatchery for rearing larvae of Macrobrachium rosenbergii. Proc. Food-drugs from the sea conf., Puerto Rico, 1974, pp. 167-181.

Sukot, J. A., Gregorio, L. Escritor and K. Mintardjo, 1982. Mass production of post larvae in the brackishwater aquaculture development center (BADC) Indonesia. Giant prawn farming, (Ed) Michael, B. New, pp. 143-156.

Uno, Y., and Kwon chin soo, 1969. Larval development of Macrobrachium rosenbergii de Man reared in the hatchery. J. Tokyo Univ. Fish., 55 (2): 179-190.